Seattle Office of Labor Standards

# តើអ្នកគឺជាកម្មករ/និយោជិតក្នុងស្រុកមែនទេ?

## អ្វីដែលអ្នកត្រូវដឹង



បទប្បញ្ញត្តិស្តីពីកម្មករ/និយោជិតក្នុងស្រុកនៃទីក្រុង SEATTLE

បទប្បញ្ញត្តិស្តីពីកម្មករ/និយោជិតក្នុងស្រុកនៃទីក្រុង Seattle (Seattle Domestic Workers Ordinance ផ្តល់កិច្ចការពារកន្លែងធ្វើការជាមូលដ្ឋានដល់កម្មករ/និយោជិតក្នុងស្រុក។

កូនសៀវភៅណែនាំនេះមានព័ត៌មានអំពីកិច្ចការពារទាំងនេះ ប៉ុន្តែមិនមែន ប្រើជាដំបូន្មានផ្លូវច្បាប់ទេ។ សម្រាប់ព័ត៌មានបន្ថែម និងសំណួរផ្សេងៗ សូមទាក់ទងទៅ៖

**Seattle** Office of
Labor Standards

ទូរសព្ទទៅលេខ (206) 256-5297
laborstandards@seattle.gov
www.seattle.gov/laborstandards

ព័ត៌មានលម្អិតទាំងស្រុងអំពីបទប្បញ្ញត្តិស្តីពីកម្មករ/និយោជិតក្នុងស្រុកមាននៅ៖
www.seattle.gov/laborstandards/ordinances/domestic-workers-ordinance

# កម្មករ/និយោជិតក្នុងស្រុក៖ តើអ្នកដឹងទេ?

**បើអ្នកធ្វើការនៅក្នុងផ្ទះជា៖**

- មេដោះ
- ចុងភៅ
- អ្នកជួយថែទាំផ្ទះ
- អ្នកគ្រប់គ្រងផ្ទះ
- អ្នកសម្អាតផ្ទះ
- អ្នកថែសួន

**អ្នកមានសិទ្ធិ៖**

- ទទួលបានប្រាក់ឈ្នួលអប្បបរមា
- សម្រាកក្នុងម៉ោងធ្វើការ និងញ៉ាំអាហារដោយគ្មានការរំខាន ឬទទួលបានប្រាក់ឈ្នួលបន្ថែម បើអ្នកមិនបានសម្រាកទេ
- ឈប់សម្រាក 1 ថ្ងៃ (24 ម៉ោង) ក្រោយពីធ្វើការ 6 ថ្ងៃជាប់គ្នា សម្រាប់កម្មករ/និយោជិតដែលរស់នៅឬគេងនៅកន្លែងធ្វើការ
- រក្សាទុកឯកសារ និងវត្ថុផ្ទាល់ខ្លួនទាំងអស់របស់អ្នក
- ទទួលបានកិច្ចការពារទល់នឹងការបៀតបៀនផ្លូវភេទ និងការរើសអើង

*បើអ្នកជានិយោជិត អ្នកមានសិទ្ធិក្រោមស្តង់ដារការងារផ្សេងទៀត

សិទ្ធិទទួលបាន

# ប្រាក់កម្រៃ អប្បបរមា

កម្មករ /និយោជិតក្នុងស្រុកទាំងអស់ត្រូវតែទទួលបានយ៉ាងតិចស្មើនឹងប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នរបស់ទីក្រុង Seattle។ រៀងរាល់ឆ្នាំប្រាក់ឈ្នួលអប្បបរមារបស់ទីក្រុង Seattle កើនឡើងនៅថ្ងៃទី 1 ខែមករា។ Office of Labor Standards (OLS, ការិយាល័យស្តង់ដារពលកម្ម) ប្រកាសអំពីកំណើនប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំនាពេលខាងមុខ នៅត្រឹមរដូវស្លឹកឈើជ្រុះរាល់ឆ្នាំ។

ដើម្បីមើលប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន សូមចូលមើល៖
www.seattle.gov/laborstandards/ordinances/minimum-wage



សិទ្ធិទទួលបាន

# ការសម្រាកក្នុងម៉ោងធ្វើការ ដោយមានប្រាក់ឈ្នួល

បើអ្នកធ្វើការលើសពី 4 ម៉ោង អ្នកត្រូវតែទទួលបានការសម្រាក 10 នាទីក្នុងម៉ោងធ្វើការដោយគ្មានការរំខាន និងមានប្រាក់ឈ្នួល មុនពេលចប់ម៉ោងធ្វើការទី 3។

**បើអ្នកធ្វើការក្នុងម៉ោងសម្រាក មានន័យថាគេជំពាក់ប្រាក់ឈ្នួលអ្នកស្មើនឹង 10 នាទីបន្ថែម។**





សិទ្ធិទទួលបាន

# ការសម្រាក ញ៉ាំអាហារ

បើអ្នកធ្វើការលើសពី 5 ម៉ោង អ្នកទទួលបានការសម្រាកញ៉ាំអាហារ 30 នាទីដោយគ្មានការរំខាន និងគ្មានប្រាក់ឈ្នួល។

ប៉ុន្តែបើអ្នកត្រូវតែនៅកន្លែងធ្វើការអំឡុងពេលសម្រាកញ៉ាំអាហារ និងត្រៀមទៅធ្វើការវិញបានភ្លាមៗ ការសម្រាកនេះត្រូវតែមានប្រាក់ឈ្នួល។

**បើអ្នកធ្វើការក្នុងម៉ោងញ៉ាំអាហារ អ្នកទទួលបានប្រាក់ឈ្នួលស្មើនឹង30នាទីបន្ថែមដោយសារមិនបានសម្រាក។**



សិទ្ធិទទួលបាន

# ថ្ងៃឈប់សម្រាក

បើអ្នករស់នៅឬគេងនៅកន្លែងធ្វើការ និងធ្វើការ 6 ថ្ងៃជាប់គ្នា អ្នកមានសិទ្ធិទទួលបានការសម្រាករយៈពេល 24 ម៉ោងដោយគ្មានប្រាក់ឈ្នួល។



សិទ្ធិរក្សាទុក

# ឯកសារផ្ទាល់ខ្លួនទាំងអស់

អ្នកមានសិទ្ធិរក្សាទុកឯកសារដើម
និងវត្ថុផ្ទាល់ខ្លួនរបស់អ្នកបាន។

# សិទ្ធិរួចផុតពីការរើសអើង និងការសងសឹក

កម្មករ/និយោជិតក្នុងស្រុកច្រើនតែធ្វើការម្នាក់ឯង និងអាចប្រឈមនឹងហានិភ័យនៃការបៀតបៀនផ្លូវភេទ ក៏ដូចជាការរើសអើងតាមរូបភាពផ្សេងទៀត។ កម្មករ/និយោជិតក្នុងស្រុកមានសិទ្ធិទទួលបានកិច្ចការពារទល់នឹងការប្រព្រឹត្តដូច្នេះក្រោមច្បាប់របស់ទីក្រុងស្តីពីការអនុវត្តដោយយុត្តិធម៌ចំពោះការងារ (Fair Employment Practices)។

និយោជកមិនអាចចាត់វិធានការលើអ្នក ដោយសារបានប្រើសិទ្ធិរបស់អ្នក ឬបានដាក់បណ្តឹងទៅទីក្រុងឡើយ។

**បើអ្នកជាកម្មករ/និយោជិតដែលចង់ពិភាក្សាអំពីសិទ្ធិរបស់អ្នក សូមទាក់ទងទៅការិយាល័យទទួលបន្ទុកផ្នែកសិទ្ធិពលរដ្ឋនៃទីក្រុង Seattle តាមរយៈលេខ (206) 684-4500 អ៊ីមែល discrimination@seattle.gov ឬគេហទំព័រ www.seattle.gov/civilrights។**

# ការិយាល័យស្តង់ដារការងារ នៃទីក្រុង SEATTLE (OLS)

ការិយាល័យស្តង់ដារពលកម្មនៃទីក្រុង Seattle នៅទីនេះដើម្បីជួយកម្មករ/និយោជិតឱ្យយល់ដឹង អំពីសិទ្ធិរបស់ខ្លួន។ ការិយាល័យ OLS ក៏ស៊ើបអង្កេត និងដោះស្រាយការបំពានច្បាប់ផងដែរ។

បើមានសំណួរផ្សេងៗឬចង់រាយការណ៍អំពីការបំពានសូមទូរសព្ទទៅលេខ(206)256-5297ឬផ្ញើអ៊ីមែល ទៅ laborstandards@seattle.gov។

# ការសន្យារបស់យើង

យើងនៅទីនេះដើម្បីជួយអ្នក។ យើងនឹងផ្តល់សេវាបកប្រែភាសាផ្ទាល់មាត់ ហើយសេវារបស់យើងគឺ ឥតគិតថ្លៃ។ យើងនឹងមិនសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។

ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែមអំពីលក្ខខណ្ឌតម្រូវទាំងនេះ សូមមើលព័ត៌មានថ្មីៗលើ គេហទំព័ររបស់យើង៖ www.seattle.gov/laborstandards

# ការិយាល័យស្តង់ដារការងារ នៃទីក្រុង SEATTLE (OLS)

ការិយាល័យស្តង់ដារពលកម្មនៃទីក្រុង Seattle ចង់ជួយ អង្គភាពជួលឱ្យយល់ដឹងអំពីភារកិច្ចរបស់ខ្លួនក្រោមច្បាប់ថ្មីនេះ។

បើមានសំណួរផ្សេងៗ សូមទូរសព្ទទៅលេខ (206) 256-5297 ឬផ្ញើអ៊ីមែលទៅ laborstandards@seattle.gov។

# ការសន្យារបស់យើង

យើងនៅទីនេះដើម្បីជួយអ្នក! យើងចង់ឱ្យអ្នកហៅទូរសព្ទមកសួរសំណួរអំពីរបៀបអនុវត្តច្បាប់ថ្មីនេះ។ ការិយាល័យស្តង់ដារពលកម្មនៃទីក្រុង Seattle នឹងផ្តល់ដំបូន្មានជាឯកជន ហើយនឹងមិនរាយការណ៍អំពីអ្នកប្រាប់មន្ត្រីអនុវត្តច្បាប់របស់យើងឡើយ។យើងរក្សាការសម្ងាត់អំពីសំណួររបស់អ្នក។

ដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែមអំពីលក្ខខណ្ឌតម្រូវទាំងនេះសូមមើលព័ត៌មានថ្មីៗលើគេហទំព័ររបស់យើង៖ www.seattle.gov/laborstandards

# កិច្ចការពារពីការរើសអើង និងការសងសឹក

កម្មករ/និយោជិតក្នុងស្រុកច្រើនតែធ្វើការម្នាក់ឯង និងអាចប្រឈមនឹងហានិភ័យនៃការបៀតបៀនផ្លូវភេទ ក៏ដូចជាការរើសអើងតាមរូបភាពផ្សេងទៀត។ កម្មករ/និយោជិតក្នុងស្រុកមានសិទ្ធិទទួលបានកិច្ចការពារទល់នឹងការប្រព្រឹត្តដូច្នេះ ក្រោមច្បាប់របស់ទីក្រុងស្ដីពីការអនុវត្តដោយយុត្តិធម៌ចំពោះការងារ។

អង្គភាពជួលនឹងរងការពិន័យបន្ថែម បើពួកគេចាត់វិធានការលើកម្មករ/និយោជិតក្នុងស្រុកដោយសារបានប្រើសិទ្ធិរបស់ខ្លួន ឬបានដាក់បណ្ដឹងទៅទីក្រុង។

**បើអ្នកចង់ដឹងបន្ថែមអំពីច្បាប់ស្ដីពីការអនុវត្តដោយយុត្តិធម៌ចំពោះការងារ សូមទាក់ទងទៅការិយាល័យទទួលបន្ទុកផ្នែកសិទ្ធិពលរដ្ឋនៃទីក្រុង Seattle តាមរយៈលេខ (206) 684-4500 អ៊ីមែល discrimination@seattle.gov ឬគេហទំព័រ www.seattle.gov/civilrights។**



[illegible]
[illegible]

# [illegible]
# [illegible]



សិទ្ធិទទួលបាន

# ថ្ងៃឈប់សម្រាក

អង្គភាពជួលត្រូវតែផ្តល់ការសម្រាករយៈពេល24ម៉ោង ដោយគ្មានប្រាក់ឈ្នួលដល់កម្មករ/និយោជិត ក្នុងស្រុកដែលរស់នៅឬគេងនៅកន្លែងធ្វើការនៅពេល ពួកគេធ្វើការ 6 ថ្ងៃជាប់គ្នា។



សិទ្ធិទទួលបាន

# ការសម្រាក ញ៉ាំអាហារ

អង្គភាពជួលត្រូវតែផ្តល់ការសម្រាកញ៉ាំអាហារ 30 នាទីដោយគ្មានការរំខាន និងគ្មានប្រាក់ឈ្នួលដល់កម្មករ/និយោជិតក្នុងស្រុក បើពួកគេធ្វើការលើសពី 5 ម៉ោង។

ប៉ុន្តែអ្នកត្រូវតែផ្តល់ប្រាក់ឈ្នួលដល់កម្មករ/និយោជិតសម្រាប់ការសម្រាកញ៉ាំអាហារ បើអ្នកតម្រូវឱ្យកម្មករ/និយោជិតនៅកន្លែងធ្វើការអំឡុងពេលសម្រាកនេះ និងត្រៀមទៅធ្វើការវិញបានភ្លាមៗ។

**បើកម្មករ/និយោជិតធ្វើការក្នុងម៉ោងញ៉ាំអាហារអ្នកត្រូវតែផ្តល់ប្រាក់ឈ្នួលស្មើនឹង 30 នាទីបន្ថែមដល់កម្មករ/និយោជិតដោយសារមិនបានសម្រាក។**



សិទ្ធិទទួលបាន

# ការសម្រាកក្នុងម៉ោងធ្វើការ ដោយមានប្រាក់ឈ្នួល

អង្គភាពជួលត្រូវតែផ្តល់ឱ្យកម្មករ/និយោជិតក្នុងស្រុកនូវការសម្រាក 10 នាទីក្នុងម៉ោងធ្វើការដោយគ្មានការរំខាន និងមានប្រាក់ឈ្នួល មុនពេលចប់ម៉ោងធ្វើការទី 3។

**បើកម្មករ/និយោជិតធ្វើការក្នុងម៉ោងសម្រាក អ្នកត្រូវតែផ្តល់ប្រាក់ឈ្នួលស្មើនឹង 10 នាទីបន្ថែមដល់កម្មករ/និយោជិត។**



សិទ្ធិទទួលបាន

# ប្រាក់កម្រៃអប្បបរមា

កម្មករ/និយោជិតក្នុងស្រុកទាំងអស់ត្រូវតែទទួលបានយ៉ាងតិចស្មើនឹង ប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្នរបស់ទីក្រុង Seattle។ រៀងរាល់ឆ្នាំ ប្រាក់ឈ្នួលអប្បបរមារបស់ទីក្រុង Seattle កើនឡើងនៅថ្ងៃទី 1 ខែមករា។ ការិយាល័យស្តង់ដារពលកម្មប្រកាសអំពីកំណើនប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំនាពេលខាងមុខ នៅត្រឹមរដូវស្លឹកឈើ ជ្រុះរាល់ឆ្នាំ។



ដើម្បីមើលប្រាក់ឈ្នួលអប្បបរមាបច្ចុប្បន្ន សូមចូលមើល៖
www.seattle.gov/laborstandards/ordinances/minimum-wage

- :ហបរឌេលេមឡទ្ទលគំរួលកើលបុឃោលទីទលញ្ញះទ្ជ័ទ្រនាញ្ញពុធីបអ៊ី
- លញឹយយេឡើអពាគីព្រុរលេមឺ:ហបឹលពុទទុបនេទទុទគេលញ្ញលម័ត់
- មុនេទពុទ្រទេទគូរយេឡើលេញ្ញលម័ត់

៖នាគយេរីពុខេទបាកិពុបំមញ្ញហោទ្ទ/រយេគ័បះយរទូមិរទ់អទគូះទារុវិច

ៃៈទារុវិចទយរួបអ៊ីដ្រពាទុទគេ ៈទារុវិចគយេរីមញ្ញហោទ្ទ/រយេគ័បលុមពរទ្ទឹលួពុបុរបអ៊ិឡួរ
ទ័រ្គ ៃមញ្ញហោទ្ទ/រយេគ័បលុញ្ញរយរយេឡើបូលុឆ័ររបេះយរទូរមិរលខលទីទលញ្ញ „លញឹយយេឡើអ„
ព្រម្មះនោទេហុ៍គប៉ា បស៍រីពុបំគ័បុរលរលុឆ័ខ្ទែបទៃរាពេញ្ញាទុព្រទហុ៍គប៉ារឡួរបអ៊ិឡួរ

ៃ„លញឹយយេឡើអ„
ដ្រគរិព្រយ្រាទេហោរមិរះទាទេបរាកិទហុ៍គប៉ាក៏ រលេមឺ លម័ត់លុហ ៃៈទារុវិចគយេ
ម័រទ់អមុ្បរមិរលុឆ្ពីពាព្រ្ញាបស៍រីពុបំមញ្ញហោទ្ទ/រយេគ័បលញឹលញ្ញទហុ៍គប៉ាពុទ្ទ រលេមឺ លម័ត់

# ៈនាស្រ្តបអ៊ី
# ៈយរទូម័រទ់អះទារុវិចម្ទា

# តើអ្នកដឹងទេ?

បើអ្នកមានការងារដែលធ្វើនៅក្នុង ឬនៅជុំវិញផ្ទះ អ្នកគួរតែដឹងអំពីបទប្បញ្ញត្តិស្ដីពីកម្មករ/និយោជិតក្នុងស្រុកនៃទីក្រុង Seattle

**អ្នកត្រូវបានចាត់ទុកជាអង្គភាពជួលដែលត្រូវអនុវត្តច្បាប់ បើអ្នកផ្ដល់ប្រាក់ឈ្នួលសម្រាប់សេវាកម្មទាំងនេះ៖**

- មេដោះ
- ចុងភៅ
- អ្នកជួយថែទាំផ្ទះ
- អ្នកគ្រប់គ្រងផ្ទះ
- អ្នកសម្អាតផ្ទះ
- អ្នកថែសួន

**អង្គភាពជួលត្រូវតែផ្ដល់ឱ្យកម្មករ/និយោជិតក្នុងស្រុកនូវចំណុចទាំងនេះ៖**

- ទទួលបានប្រាក់ឈ្នួលអប្បបរមា
- សម្រាកក្នុងម៉ោងធ្វើការ និងញ៉ាំអាហារដោយគ្មានការរំខាន ឬផ្ដល់ប្រាក់ឈ្នួលបន្ថែម បើពួកគេមិនបានសម្រាកទេ
- ឈប់សម្រាក 1 ថ្ងៃ (24 ម៉ោង) ក្រោយពីធ្វើការ 6 ថ្ងៃជាប់គ្នា សម្រាប់កម្មករ/និយោជិតដែលរស់នៅឬគេងនៅកន្លែងធ្វើការ
- សិទ្ធិរក្សាទុកឯកសារ និងវត្ថុផ្ទាល់ខ្លួនទាំងអស់
- ទទួលបានកិច្ចការពារទល់នឹងការបៀតបៀនផ្លូវភេទ និង

*បើអ្នកជានិយោជក អ្នកមានកាតព្វកិច្ចក្រោមស្តង់ដារការងារផ្សេងទៀត

បទប្បញ្ញត្តិស្តីពីកម្មករ/និយោជិតក្នុងស្រុកនៃទីក្រុង Seattle ផ្តល់កិច្ចការពារកន្លែងធ្វើការជាមូលដ្ឋានដល់កម្មករ/និយោជិតក្នុងស្រុក។

កូនសៀវភៅណែនាំនេះមានព័ត៌មានអំពីកិច្ចការពារទាំងនេះ ប៉ុន្តែមិនមែន ប្រើជាដំបូន្មានផ្លូវច្បាប់ទេ។ សម្រាប់ព័ត៌មានបន្ថែម និងសំណួរផ្សេងៗ សូមទាក់ទងទៅ៖

**Seattle** Office of
Labor Standards

ទូរសព្ទទៅលេខ (206) 256-5297
laborstandards@seattle.gov
www.seattle.gov/laborstandards

ព័ត៌មានលម្អិតទាំងស្រុងអំពីបទប្បញ្ញត្តិស្តីពីកម្មករ/និយោជិតក្នុងស្រុកមាននៅ៖
www.seattle.gov/laborstandards/ordinances/domestic-workers-ordinance

**Seattle** Office of
Labor Standards

# កំពុងជួលកម្មករ/និយោជិតក្នុងស្រុកឬ? អ្វីដែលអ្នកត្រូវដឹង



បទប្បញ្ញត្តិស្តីពីកម្មករ/និយោជិតក្នុងស្រុកនៃទីក្រុង SEATTLE